# រាជបណ្ឌិត្យសភាកម្ពុជា

# លទ្ធផលកិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៅខែមីនា ឆ្នាំ២០១៨

( ចងក្រងដោយ៖ RAC Media; ប្រភពឯកសារ៖ កជភខ )

## ១-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៨

ថ្ងៃអង្គារ ៥រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ជួរ គារី បានប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការទស្សនវិជ្ជា បានចំនួន០២ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- តាវនិយម<br>អ.Taoism<br>បារ. Taoïsme | ទស្សនវិជ្ជាចិនបុរាណដែលមានអត្ថន័យពីរយ៉ាង៖<br>ទីមួយ គឺជាទស្សនវិជ្ជាស្ដីអំពីភាពសាមញ្ញនិងភាពមិនជ្រៀតជ្រែក ពោលគឺសំដៅយកទស្សនវិជ្ជាចិនដែលគាំទ្រជីវិតសាមញ្ញនិងគោលការណ៍នៃការមិនជ្រៀតជ្រែកដំណើរវិវត្តន៍បែបធម្មជាតិរបស់អ្វីមួយ។ តាវនិយម ត្រូវបានគេរកឃើញក្នុងសតវត្សរ៍ទី៦ មុនគ្រិស្តសករាជ ដោយ ឡៅស៊ី (Lao-tzu) ដែលជាទស្សនវិទូនិងអ្នកអធិធម្មជាតិ។<br>ទីពីរ គឺជាសាសនាពេញនិយមរបស់ចិនដែលស្វែងរកសុខដុមនិងអាយុវែងតាមរយៈទស្សនវិជ្ជារបស់តាវនិយម ដែលផ្សំពីអាទិទេពធម្មជាតិនិងការប្រតិបត្តិខាងវេទមន្ត។ |
| ២. និព្វាន<br>អ. Nirvana<br>បារ. Nirvana | និព្វានត្រូវបានបកស្រាយខុសៗគ្នាដូចខាងក្រោម៖<br>- ឈ្មោះធម្មជាតឬចិត្តដែលចេញចាកផុតពីកិលេសនិងតណ្ហាអស់មានកម្ម ជាអ្នកគាត់តែងនាំឱ្យមានការកើតក្នុងវដ្តនិងជាទីបរមសុខស្ងប់ដែលកើត ចេញពីសីលសមាធិ និងបញ្ញា។<br>- សភាពឥតខ្ចោះឬបរមសុខនិងភាពស្ងប់ ដែលកើតឡើងដោយការរំលត់ចំណង់និងតណ្ហា និង ភាពអស្ចារ្យក្នុងការផ្ដាច់អត្តិភាពរបស់អត្តៈ។<br>(ពុទ្ធសាសនា)<br>- ការរួបរួមឬការដឹងអំពីអត្តសញ្ញាណនៃអាត្ម័នជាមួយព្រហ្មន៍ដែលគេជឿថាអាត្ម័ននេះមានភាពអមតៈ(Brahman)។ (ហិណ្ឌូសាសនា)<br>- ការរំដោះព្រលឹងចេញពីទាសភាពនៃកម្មនិងសំសារៈ ហើយវាក៏មានន័យថាជាគោលដៅសង្គ្រោះផងដែរ។ (ជេនសាសនា)<br>(វេវចនៈនឹងពាក្យនិព្វាន មានដូចជា និរវាណ មោក្ស មោក្ខ វិមុត្តិ ជាដើម) |

## ២-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨

នៅរសៀលថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ កន្លងទៅនេះ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ បានបន្តប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច បានចំនួន០៤ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- ផលិតផល<br>អ. product<br>បារ. produit(m.) | ទំនិញឬសេវាដែលបានបង្កើតឡើងដើម្បីបំពេញតម្រូវការអតិថិជនដោយអាចរួមបញ្ចូលទាំងព័ត៌មានអំពីធាតុផ្សំ អត្ថប្រយោជន៍ លក្ខណៈពិសេស របៀបប្រើប្រាស់។ល។ |
| ២- សហគ្រិនភាព<br>អ. entrepreneurship<br>បារ. esprit d’entreprise(m.) | សមត្ថភាពនិងឆន្ទៈ ដើម្បីបង្កើត ចាត់ចែង និងគ្រប់គ្រងអាជីវកម្ម ណាមួយដែលអាចមានហានិភ័យ ក្នុងគោលបំណងទទួលបានប្រាក់ ចំណេញនិងធានាបាននូវសុខមាលភាពសង្គម។<br>ចរិតនៃសហគ្រិនភាពកំណត់ដោយនវានុវត្តន៍និងការប្រឈមនឹងហានិភ័យ។ |
| ៣- ច្រកបែងចែក<br>អ. distribution channel<br>បារ. chaîne de distribution(f.)<br>/canal de distribution(m.) | ផ្លូវដែលទំនិញនិងសេវាត្រូវបានចែកចាយដោយគិតចាប់ពីក្រោយការផលិតរហូតដល់ការប្រើប្រាស់។ |
| ៤- កម្រៃជើងសា<br>អ. commission<br>បារ. commission(f.) | ភាគរយនៃថ្លៃទំនិញឬអត្ថប្រយោជន៍(ទំនិញ របស់ ប្រាក់...)ដែល ភ្នាក់ងារទិញលក់ឬភ្នាក់ងារដទៃទៀតត្រូវបានទទួលក្នុងទំនាក់ទំនង ការងារនោះ។ |

## ៣-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨

កាលពីថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ បានបន្តប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច បានចំនួន០៣ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- ថ្លៃ<br>អ. price<br>បារ. prix (m.) | ចំនួនប្រាក់នៃតម្លៃទំនិញឬសេវាចេញមកពីការដោះដូរ។ |
| ២- ថ្លៃលក់ផ្ដាច់<br>អ. sale price<br>បារ. prix soldé (m.) | ថ្លៃទំនិញឬសេវាដែលលក់ដោយមានការបញ្ចុះថ្លៃរួច។ |
| ៣- ថ្លៃទីផ្សារ<br>អ. market price<br>បារ. prix (m.) de marché | ថ្លៃទិញឬលក់ជាទូទៅនៃទំនិញឬសេវានៅលើទីផ្សារ។ |
| ៤- ថ្លៃកម្រិត<br>អ. fixed price<br>បារ. prix fixe (m.) | ថ្លៃទំនិញឬសេវាដែលមិនអាចតថ្លៃបាន។ |